# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៥៩៣ .....សហវ.....

ថ្ងៃព្រហស្បតិ៍ ៣កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ ២០១៩

**ជម្រាបជូន**

**ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា**

**កម្មវត្ថុ៖** ករណីសំណើសុំគោលការណ៍ចំណាយថវិកាប្រចាំឆ្នាំ សម្រាប់ចំណាយលើការផ្តល់រង្វាន់ **សាលាស្អាត** វិញ្ញាបនបត្រទទួលស្គាល់ជ័យលាភី និងថវិកាលើកទឹកចិត្តអមពានរង្វាន់ដល់ជ័យលាភីសាលាស្អាត ។

**យោង៖** លិខិតលេខ៦២៤៧ អយក.បស ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ក្រសួងអប់រំ យុវជន និងកីឡា ។

តបតាមន័យដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តមបណ្ឌិតសភាចារ្យ** ជ្រាបថា ក្នុងគោលដៅជំរុញឱ្យយុទ្ធនាការសាលារៀនស្អាតនៅគ្រប់សាលារៀន ឱ្យមានប្រសិទ្ធភាពខ្ពស់ សំដៅលើកកម្ពស់បរិស្ថានល្អ និងមានអនាម័យនៅតាមសាលារៀន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានពិនិត្យនិងឯកភាពជាគោលការណ៍ផ្តល់ពានរង្វាន់ សាលាស្អាត វិញ្ញាបនបត្រទទួលស្គាល់ជ័យលាភី និងថវិកាលើកទឹកចិត្តអមពានរង្វាន់ជ័យលាភីដល់សាលាស្អាតចំនួន ០៥ ក្នុងក្របខ័ណ្ឌទូទាំងប្រទេស ដែលត្រូវបានជ្រើសរើសដោយក្រសួងអប់រំ យុវជន និងកីឡា ចាប់ពីឆ្នាំ២០១៩ តទៅ ដូចខាងក្រោម ÷

១- ពានរង្វាន់ចំនួន ០១ (មួយ) តាមគំរូដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា

២- វិញ្ញាបនបត្រទទួលស្គាល់ជ័យលាភីសាលាស្អាតចំនួន០១ (មួយ) ដែលចេញដោយក្រសួងអប់រំ យុវជន និងកីឡា

៣- ថវិកាលើកទឹកចិត្តអមពានរង្វាន់ តាមគោលការណ៍ដូចខាងក្រោម÷

- សាលាស្អាតចំណាត់ថ្នាក់លេខ ១ ទទួលថវិកាអម ចំនួន ៥ ០០០ ០០០៖០០
- សាលាស្អាតចំណាត់ថ្នាក់លេខ ២ ទទួលថវិកាអម ចំនួន ៤ ០០០ ០០០៖០០
- សាលាស្អាតចំណាត់ថ្នាក់លេខ ៣ ទទួលថវិកាអម ចំនួន ៣ ០០០ ០០០៖០០

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ័ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

-សាលាស្អាតចំណាត់ថ្នាក់លេខ ៤ ទទួលថវិកាអម ចំនួន ៣ ០០០ ០០០៖០០

-សាលាស្អាតចំណាត់ថ្នាក់លេខ ៥ ទទួលថវិកាអម ចំនួន ៣ ០០០ ០០០៖០០។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម** ជ្រាប និងចាត់ចែងតាមការគួរ ។

សូម **ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** មេត្តាទទួលនូវគារវកិច្ចពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

<u>ចម្លងជូន÷</u>

-អគ្គនាយកដ្ឋានរតនាគារជាតិ

-ឯកសារ-កាលប្បវត្តិ